ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៤១

ចុះថ្ងៃទី ០២-០៨-២០១៦

សាលដីកា

លេខ ១៣ ក្រII "ល"

ចុះថ្ងៃទី ២០-០២-២០១៧

# គាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤១ ចុះថ្ងៃទី ០២-០៨-២០១៦ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ[redacted]ហៅ ឡាធំ ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ ៣ សង្កាត់ទំនប់រលក ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ រាសយដ្ឋានសព្វថ្ងៃនៅភូមិដំណាក់ចំបក់ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប ឪពុកឈ្មោ[redacted]" ម្តាយឈ្មោះ [redacted]" នៅលីវ ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨៣៩ តព្រ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

២-ជនជាប់ចោទឈ្មោះ [redacted] ហៅ ពយ ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ កប់ស្រូវ សង្កាត់គោករកា ខណ្ឌសែនសុខ ក្រុងភ្នំពេញ រាសយដ្ឋានសព្វថ្ងៃនៅភូមិចំការស្វាយ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]" ម្តាយឈ្មោ[redacted] នៅលីវ ទោសពីមុនគ្មាន។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៧៦៧ តព្រ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៥)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។





Scanned by CamScanner

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់វត្ថុដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៤៥E០ ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣.០៦.២០១៥ និងប្រព្រឹត្តនៅចំណុចមុខសាលារៀនទួលស្វាយព្រៃ ផ្លូវលេខ១៩៩ ក្រុម២៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២.០៧. ២០១៥ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ និង មាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ២២ឆ្នាំ មានអាសយដ្ឋានផ្ទះជួល ផ្លូវលេខ១៨៥ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ៤៥ ផ្លូវលំ ក្រុម៥០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៣២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ប្ដឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៤ "ប" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោ [redacted] ឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៤ "ប" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ១៣.០៦.២០១៥ មានករណីលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់វត្ថុដោយគ្មានការអនុញ្ញាត (ប្លន់ប្រដាប់អាវុធ យកម៉ូតូ) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៤៥E០ ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣.០៦.២០១៥ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ ប៊ិក ឈ្មោះ [redacted] ហៅ ពយ និងជនជាប់ចោទឈ្មោ [redacted] ដោយប្រើកាំភ្លើងម៉ាក ក៥៤ បាញ់ទៅលើជនរងគ្រោះឈ្មោះ [redacted] ដោយយកបាននូវម៉ូតូម៉ាកឌូក ហើយយកទៅលក់ឲ្យឈ្មោ [redacted] លុះនៅថ្ងៃទី ០២.០៧.២០១៥ មានករណីលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់វត្ថុដោយគ្មានការអនុញ្ញាត (ប្លន់ប្រដាប់អាវុធយកម៉ូតូ) ប្រព្រឹត្តនៅចំណុចមុខសាលារៀនទួលស្វាយព្រៃ ផ្លូវលេខ១៩៩ ក្រុម២៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ហៅ ឡាធំ ឈ្មោះ [redacted] ហៅ ប៊ិក និងជនជាប់ចោទឈ្ម [redacted] ព្រមទាំងបក្សពួក បានធ្វើសកម្មភាពប្លន់ដោយប្រើកាំភ្លើងខ្លីម៉ាក ក៥៤ បាញ់ទៅលើជនរងគ្រោះឈ្មោ [redacted] ដោយយកបាននូវម៉ូតូម៉ាកស្កូពី ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ ១CQ-២៨០៥ ។



Scanned by CamScanner

*រឿងក្តីនេះ សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៤ "ប" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦ ដែលមានខ្លឹមសារដូចតទៅ ៖*

១-ផ្តន្ទាទោសលើ៖

ក-ឈ្មោះ [redacted] ហៅ ឡាធំ ភេទប្រុស អាយុ ២០ឆ្នាំ ។

ខ-ឈ្មោះ [redacted] ហៅ ប៊ិក ភេទប្រុស អាយុ ១៩ឆ្នាំ ។

គ-ឈ្មោះ [redacted] ហៅ ពយ ភេទប្រុស អាយុ ១៨ឆ្នាំ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៦ (ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ២ (ពីរ)លានរៀល ។

ឃ-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១ (មួយ)លានរៀល ។

ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៤៥Eo ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣.០៦.២០១៥ ។

បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ៣៥៧ និងមាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២-ផ្តន្ទាទោសលើ:

ក-ឈ្មោះ [redacted] ហៅ ឡាធំ ភេទប្រុស អាយុ ២០ឆ្នាំ ។

ខ-ឈ្មោះ [redacted] ហៅ ប៊ិក ភេទប្រុស អាយុ ១៩ឆ្នាំ ។

គ-ឈ្មោះ [redacted] ហៅ ពយ ភេទប្រុស អាយុ ១៨ឆ្នាំ ។

ដាក់ពន្ធនាគារគារក្នុងម្នាក់ៗកំណត់ ៦(ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ២(ពីរ)លានរៀល ។

ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខសាលារៀនទួលស្វាយព្រៃ ផ្លូវលេខ១៩៩ ក្រុម២៤ ភូមិ៥ សង្កាត់ ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២.០៧.២០១៥។

បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៧ និងមាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្តន្ទាទោសលើឈ្មោះ [redacted] ហៅ ណុប ភេទប្រុស អាយុ ៤១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣ (បី)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន ៨ (ប្រាំបី)ខែ ទោសសល់ពីនេះព្យួរធម្មតាទាំងអស់ និងពិន័យជាប្រាក់ចំនួន ២ (ពីរ)លានរៀល ។

ពីបទ លក់អាវុធដោយគ្មានការអនុញ្ញាត និងទទួលផលចោរកម្ម ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ៤៥Eo ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣.០៦.២០១៥ ។

បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ៩៧ មាត្រា ១០៨ មាត្រា ៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned by CamScanner

៤-រឹបអូសវត្ថុចាប់យកនូវ:

ក-ម៉ូតូ ០១គ្រឿង ម៉ាកសេ ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ ស្លាកលេខ ភ្នំពេញ ១CV-0469 លេខតួ និងលេខម៉ាស៊ីន 9246684 ។

ខ-ស្លាកលេខម៉ូតូ 1CM-4453 ភ្នំពេញ 1CM-1287 ភ្នំពេញ 1BD-1048 ភ្នំពេញ និងថ្នាំលាងរឺបូសចំនួន ០២ដប ។

គ-អាវុធខ្លីម៉ាក K54 ចំនួន ០១ដើម ផលិតនៅប្រទេសសូវៀត លេខ ១២៨៥ គ្រាប់ចំនួន ០៥គ្រាប់ និងបង់មួយ ។

ឃ-ស្បែកជើងផ្ទាត់ ០១គូ ពណ៌ស ។

៥-ប្រគល់វត្ថុចាប់យក នូវ: ទូរស័ព្ទដៃចំនួន ៣គ្រឿង គឺម៉ាកណូគា ចុចពិល ចំនួនមួយគ្រឿង ពណ៌ខ្មៅ ។ ម៉ាក សាំសុងចំនួនមួយគ្រឿង ពណ៌ស និងម៉ាកអាយហ្វូន ៥ ចំនួនមួយគ្រឿង ឲ្យទៅម្ចាស់ដើមវិញ ។

៦-បង្គាប់ឲ្យឈ្មោះ[redacted]ហៅ ឡាធំ, ឈ្មោ[redacted]ហៅ ហ៊ា, ឈ្មោ[redacted]ហៅ ពយ ,ឈ្មោះ [redacted]ងឈ្មោះ[redacted]ហៅ ណុប រួមគ្នា សងការខូចខាតចំនួន ៥៥០០ (ប្រាំពាន់ប្រាំរយ)ដុល្លារ អាមេរិក ឲ្យឈ្មោះ ម៉ៅ រិទ្ធ ។ ការទាមទារលើសពីនេះបដិសេធចោល ។ តាមមាត្រា ៣៥៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ១៧-១១-២០១៦ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២៨-១១-២០១៦ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះទី២លេខ ៣២ ដក ២០១៦ ចុះថ្ងៃទី ១០-១១-២០១៦។

## នាពេលសវនាការ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted](អវត្តមាន)

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted](អវត្តមាន)

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

- ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា៖ ខ្លួនប្តឹងឧទ្ធរណ៍មកនេះដោយសារតែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុខ្លួនបានទៅជាមួយបក្សពួក ដោយសារតែជាមិត្តភក្តិគឺដើម្បីទៅដើរលេង។ អង្គហេតុថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ ខ្លួនបានចូលរួមតែមិនមែនជាអ្នកកាន់កាំភ្លើងទេ ចំពោះអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមទេ គឺខ្លួនគ្រាន់តែជិះទៅជាមួយលុះពេលឃើញគេប្រព្រឹត្តបទល្មើសខ្លួនក៏ជិះម៉ូតូចេញទៅ។ សំណូមពរឲ្យក្រុមប្រឹក្សាសម្រេចឲ្យខ្លួនរួចផុតពីបទចោទចំពោះអង្គហេតុកើតថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥។

- ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា ៖ ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន

តែពេលនេះខ្លួនបានដឹងកំហុសហើយ ពេលខ្លួនចេញទៅវិញខ្លួននឹងកែប្រែខ្លួនឱ្យក្លាយជាមនុស្សល្អឈប់ប្រព្រឹត្តបទល្មើសទៀតហើយ។ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ចម្លើយរបស់ជនជាប់ចោទមានភាពលាក់លៀម តែយ៉ាងណាក៏បានទទួលស្គាល់ពីរអង្គហេតុ ហេតុដូច្នេះសាលាដំបូងបានសម្រេចអំពីទណ្ឌកម្ម និងពិរុទ្ធភាពឃើញថាត្រឹមត្រូវហើយ ចំពោះការប្រកាសទោសពីរផ្សេងគ្នាក្នុងសាលក្រមនេះ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចអនុវត្តទោសត្រួតគ្នាចំពោះអង្គហេតុទាំងពីរនេះដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានថាចំពោះអង្គហេតុថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ កូនក្តីខ្លួនបានសារភាពថាបានចូលរួមប្រព្រឹត្ត ប៉ុន្តែអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេដោយគ្រាន់តែបានជិះចូលជាមួយបក្សពួកតែប៉ុណ្ណោះសំណូមពរឱ្យក្រុមប្រឹក្សាសម្រេចលើកលែងចោទប្រកាន់លើកូនក្តីខ្លួនចំពោះអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]ធ្វើសេចក្តីសន្និដ្ឋានថាក្រោយពីបានស្តាប់ការដេញដោលឃើញថាកូនក្តីខ្លួនបានសារភាពទទួលស្គាល់កំហុស ហើយមានឆន្ទៈក្នុងការកែប្រែខ្លួនធ្វើជាពលរដ្ឋល្អរបស់សង្គមវិញ។ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍លេខ ៣២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៤ "ប" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះដើម្បីជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្តឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោ[redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៤ "ប" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះដើម្បីជំនុំជម្រះបានយោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned by CamScanner

៣-ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ចំពោះអង្គហេតុថ្ងៃទី១៣.០៦.២០១៥ តែចំពោះអង្គហេតុថ្ងៃទី០២.០៧.២០១៥ ខ្លួនមិនបានចូលរួមទេ ដោយគ្រាន់តែជិះទៅជាមួយពួកគេ តែពេលឃើញគេប្រព្រឹត្តបទល្មើសខ្លួនក៏ជិះម៉ូតូចេញទៅ។ ក្រុមប្រឹក្សាយល់ឃើញថា ចម្លើយសារភាពចំពោះអង្គហេតុថ្ងៃទី១៣.០៦.២០១៥ ស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងនានា និងអង្គហេតុ អាចឱ្យក្រុមប្រឹក្សាជឿបានថាជនជាប់ចោទឈ្មោះ ឃុន សុខឡា ពិតជាបានចូលរួមប្រព្រឹត្តបទល្មើសនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ ប្រាកដមែន។ ចំពោះចម្លើយបដិសេធថាមិនបានចូលរួមប្រព្រឹត្តនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ មិនអាចឱ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថាចម្លើយរបស់ជនជាប់ចោទដដែលបានឆ្លើយនាសាលាដំបូងថាខ្លួនបានចូលរួមប្រព្រឹត្តបទល្មើសនៅក្នុងអង្គហេតុនេះជាមួយបក្សពួក។ ជាងនេះទៅទៀត ចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី និងភស្តុតាងនានាឃើញថាស៊ីសង្វាក់គ្នានឹងអង្គហេតុអាចឱ្យក្រុមប្រឹក្សាជឿបានថា ជនជាប់ចោទឈ្មោះ ឃុន សុខឡា ពិតជាបានចូលរួមប្រព្រឹត្តបទល្មើសនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ប្រាកដមែន។

៤-ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយសារភាពថាខ្លួនពិតជាបានចូលរួមប្រព្រឹត្តបទល្មើសនៅក្នុងអង្គហេតុទាំងពីរករណីប្រាកដមែន ចម្លើយសារភាពនេះបានស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី ភស្តុតាង និងអង្គហេតុ អាចឱ្យក្រុមប្រឹក្សាជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៥- យោងតាមភស្តុតាងក្នុងសំណុំរឿង និងចម្លើយរបស់ជនជាប់ចោទ ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់យ៉ាងច្បាស់ថាពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោ[redacted]ងឈ្មោះ [redacted]បទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខផ្ទះ៤៥E₀ ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅចំណុចមុខសាលារៀនទួលស្វាយព្រៃ ផ្លូវលេខ១៩៩ ក្រុម២៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ យោងតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌពិតប្រាកដមែន ។

៦-តំណាងមហាអយ្យការបានសន្និដ្ឋានថា ចម្លើយរបស់ជនជាប់ចោទមានភាពលាក់លៀម តែយ៉ាងណាក៏បានទទួលស្គាល់ពីអង្គហេតុ សាលាដំបូងបានសម្រេចអំពីទណ្ឌកម្ម និងពិរុទ្ធភាពឃើញថាត្រឹមត្រូវហើយ ចំពោះការប្រកាសទោសពីរផ្សេងគ្នាក្នុងសាលក្រមនេះ ស័ណ្ឋមពរឱ្យក្រុមប្រឹក្សាសម្រេចអនុវត្តទោសត្រួតគ្នាចំពោះអង្គហេតុទាំងពីរនេះដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ។ គប្បីក្រុមប្រឹក្សាពិចារណា។

៧-លោ[redacted]មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]បានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះអង្គហេតុថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ កូនក្តីខ្លួនបានសារភាពថាបានចូលរួមប្រព្រឹត្ត ប៉ុន្តែអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេដោយគ្រាន់តែបានជិះចូលជាមួយបក្សពួកតែ



Scanned by CamScanner

ប៉ុណ្ណោះ សំណូមពរឲ្យក្រុមប្រឹក្សាសម្រេចលើកលែងចោទប្រកាន់លើកូនក្តីខ្លួនចំពោះអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥។ ក្រុមប្រឹក្សាយល់ឃើញថាការសន្និដ្ឋានរបស់មេធាវីថាកូនក្តីខ្លួនមិនជាប់ពាក់ព័ន្ធជាមួយអង្គហេតុថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១៥ ដោយគ្រាន់តែបានជិះម៉ូតូជាមួយបក្សពួក ឃើញថាមិនត្រឹមត្រូវ ទោះបីជាជនជាប់ចោទមិនមែនជាចារីផ្ទាល់ក៏ដោយ ប៉ុន្តែបានចូលរួមក្នុងនាមជាសហចារីក្នុងការប្រព្រឹត្តបទល្មើស ហេតុដូច្នេះ ការស្នើសុំឲ្យក្រុមប្រឹក្សាសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់លើអង្គហេតុថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ក្រុមប្រឹក្សាមិនពិចារណាទេ។

៨-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការដេញដោយឃើញថាកូនក្តីខ្លួនបានសារភាពទទួលស្គាល់កំហុស ហើយមានឆន្ទៈក្នុងការកែប្រែខ្លួនធ្វើជាពលរដ្ឋល្អរបស់សង្គមវិញ។ សំណូមពរឲ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។ គប្បីក្រុមប្រឹក្សាពិចារណា។

៩-ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសទាំងពីរករណី ដោយមានការចោទប្រកាន់បទល្មើសតែមួយដូចគ្នា ដូច្នេះគប្បី អនុវត្តវិធានក្នុងបទល្មើសត្រួតគ្នា ដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ យោងតាមបញ្ញត្តិមាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ។

១០-សាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៥"ប" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី មានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែការផ្តន្ទាទោសលើជនជាប់ចោទ គប្បីត្រូវកែប្រែឡើងវិញ តាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦៣ ក្រ៥ "ប" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែការផ្តន្ទាទោសលើជនជាប់ចោទ ៖

ក/-ឈ្មោះ [redacted] ត្រង់ចំណុចទី ១.ក និងចំណុចទី ២.ខ ត្រូវបដិសេធចោល និងសម្រេចជាថ្មី ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារសរុបកំណត់ ១០ (ដប់)ឆ្នាំ វិញ ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខផ្ទះ៤៥E₀ ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅចំណុចមុខភោជនីយដ្ឋានទួលស្វាយ



Scanned by CamScanner

ព្រៃ ផ្លូវលេខ១៩៨ ក្រុម២៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ យោងតាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ មាត្រា៤៩០ និងមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ ។

៣/-ឈ្មោះ [redacted]ត្រង់ចំណុចទី ១.គ និងចំណុចទី ២.គ ត្រូវបដិសេធចោល និងសម្រេចជាថ្មី ដោយផ្តន្ទាទោសដាក់ពន្ធនាគារសរុបកំណត់ ១០ (ដប់)ឆ្នាំ វិញ ពីបទ លួចដោយស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចមុខផ្ទះ៥៥E$_0$ ផ្លូវលំ ក្រុម៥០ ភូមិ១៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅចំណុចមុខសាលារៀនទួលស្វាយព្រៃ ផ្លូវលេខ១៩៨ ក្រុម២៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ យោងតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ មាត្រា ៤៩០ និងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ។

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]តាមនីតិវិធី ។

៥-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** — ហត្ថលេខា [redacted]

**ចៅក្រមប្រឹក្សា** — ហត្ថលេខា[redacted]

**ប្រធានក្រុមប្រឹក្សា** — ហត្ថលេខា[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧

ប្រធានអង្គប្រឹក្សាជំនុំជម្រះ

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner